តើអ្នកជឿលើរឿងអបិយជំនឿ មន្តអាគម ខ្មោចព្រាយបិសាចដែរឬទេ? បើជឿ តើជឿកម្រិតណាដែរ? ចុះអ្នកធ្លាប់ដឹងឮអ្វីខ្លះទាក់ទងនឹងរឿងអស់នេះ?

និទានពេជ្របណ្ឌិតមួយថ្មីនេះ បរិយាយអំពីអ្នកនិពន្ធកម្លោះម្នាក់ឈ្មោះ លោក ណាំង ប្រាថ្នា.....

---

...ស្អីនេះ....ជាសំឡេងចម្រៀងដ៏លន្លង់លន្លោច....ប៉ុន្តែពិតមិនដឹងថាជាភាសាអ្វីនោះទេ។ គ្មាននរណាស្ដាប់ឬយល់នោះឡើយ។ អ្នកនិពន្ធកម្លោះគិតថាវាគឺជារឿងនៅក្នុងសុបិនដ៏ជ្រាលជ្រៅហើយសែនចម្លែកមួយ ប៉ុន្តែពេលដែលគេបើកភ្នែកឡើងមកវិញ អារម្មណ៍ទាំងមូលប្រមូលវិលផ្ដុំមករកគ្នា....គេស្រាប់តែទទួលស្គាល់ថា មិនមែនជាសុបិនដាច់ខាត។

ពិតជាមានអ្នកណាម្នាក់កំពុងច្រៀងមកល្វើយ....សំឡេងចម្រៀងដូចជាបុរាណ ដូចជាភាសាឥណ្ឌា ដូចជាចាមបន្តិច ដូចជាបទចម្រៀងចិនចាស់ៗក្នុងរជ្ជកាលសង្គ្រាមមហាអធិរាជ សែនលន្លង់លន្លោចទោះកំណត់ភាសាមិនត្រូវ។

....អត់ទេ ជាបទចម្រៀងខ្មែរ! សូរផងនេះមិនច្រឡំជាមួយអ្នកណាទាំងអស់ គ្រាន់តែមានភាសាខ្លះស្ដាប់មិនយល់!

គេក្រោកចេញពីគ្រែជាមួយជើងទាំងគូរវែងៗ សមស្របនឹងកម្ពស់ឥតខ្ចោះរបស់គេមកពីកំណើត។ ហត្ថាលូកបើករនុកទ្វារឈើដ៏ធំមាំ ហើយរុញទ្វារបើកទៅក្រៅសន្សឹមៗ។

នេត្រាមុតស្រួចផ្ដោតសម្លឹងទៅអណ្ដូងថ្មបុរាណដ៏ធំនិងខ្ពស់មួយនៅនឹងមុខបន្ទប់គេង។ ទីនេះគឺជាភូមិចាស់ ដែលធ្លាប់មានតំណាលថា ត្រូវបានបោះបង់ចោលលែងរស់នៅមកជាច្រើនរយឆ្នាំហើយ។

តាំងពីសម័យកាលបុរាណចារ្យរហូតដល់មុខជំនាន់បារាំង ក៏នៅតែគ្មានអ្នកហ៊ានមកប្រមូលផ្ដុំគ្នារស់នៅវិញនៅឡើយ។

ទោះបីជារាជការបារាំងធ្លាប់បានគាបសង្កត់ ឱ្យបង្កើតជាមូលដ្ឋានស្នាក់ សម្រាប់កងប្រុសៗដែលត្រូវបានគេកេណ្ឌយកមក ធ្វើកសិកម្មនិងកសិ-ឧស្សាហកម្ម ក៏ក្រោយមកនៅតែមានអ្នករត់គេចចេញនិងបាត់បង់ជីវិតដោយចម្លែកជាបន្តបន្ទាប់ រហូតទាល់តែលែងមានៈហើយបិទចោលជំរំនេះវិញ។

មកដល់សម័យប៉ុលពត ក៏គ្មានអ្នកណាម្នាក់អាចរស់នៅតំបន់នេះយូរឡើយ។ ទោះបីជាអង្គការខ្មែរក្រហម បានឃោសនាមនោគមន៍វិជ្ជាឲ្យបំភ្លេចចោលរឿងអបិយជំនឿខ្មោចព្រាយបិសាចប្រមូលកងស្រួចមកនៅធ្វើពលកម្មក្នុងភូមិនេះ ប៉ុន្តែហេតុការណ៍អកុសលនៅតែកើតមានឡើង រហូតដល់ឈ្លបម្នាក់បានស្លាប់យ៉ាងចម្លែក នាំឱ្យឈ្លបជាច្រើនទៀតសម្រេចចិត្តរត់ផាសក្រញាំចេញដូចគ្នា។

ឆ្នាំ២០២២ ថ្ងៃអាទិត្យ ទី០៦ ខែកុម្ភៈ.....

«ខ្ញុំឈ្មោះណាំង ប្រាថ្នា មាននាមប៉ាកកា ស្នេរណាំងក្រាំងមាស!»

គេសរសេរញាប់ស្នេរនៅលើសៀវភៅកំណត់ហេតុតូចរបស់ខ្លួន ដែលចងភ្ជាប់ជាមួយឌីជីថលក្នុងប្រព័ន្ធភ្លោដតាមទូរសព្ទដៃសម័យទំនើប 5G។

នៅខាងក្រៅនេះ សំឡេងចម្រៀងរបស់មនុស្សស្រីបុរាណបានផុតរលត់ទៅនៅចំអណ្ដូងចាស់គ្មានទឹកដ៏ធំមួយនៅចំពីមុខបុរសកំពុងឈរ។

ផ្ទះដំបូលក្បឿងនេះ ជាទីអ្នកនិពន្ធមកស្នាក់នៅ។

ទីនេះជាផ្ទះសំណាក់ថ្មីសន្លាងរៀបចំឡើងដោយប្ដីប្រពន្ធជនជាតិបារាំង ទើបតែមករៀបចំឡើងបានប្រហែលជាបាន៥ខែតែប៉ុននោះ ។

កន្លែងនេះក៏ជាឱកាសដែលធ្វើឲ្យអ្នកនិពន្ធយើងអាចមកដល់ភូមិនេះ ជាភូមិដែលគេបានឮមកនូវព្រេងនិទានព្រឺព្រួចគួរឱ្យចាប់អារម្មណ៍តែមកមិនទាន់បានរហូតដល់ថ្ងៃនេះ.....

«លោកគ្រូសម្រាន្តមិនលក់?»

នេះគឺជាសំឡេងបុរសម្នាក់ឈ្មោះឆោម ដែលបានចេញមុខមកទទួលយុវកម្លោះយើងតាំងពីព្រឹកមិញ។

ឆោមហៅអ្នកនិពន្ធយើងថាគ្រូតាមទម្លាប់ខ្មែរអ្នកជនបទឱ្យតែអ្នកចេះដឹងគេហៅគ្រូទាំងអស់ ទាំងស្រីទាំងប្រុស។

ឈ្មោះឆោមនេះក៏ជាមនុស្សម្នាក់ដែលត្រូវបានប្រាថ្នាដឹងថា មានតួនាទីមើលថែនឹងជាអ្នកគ្រប់គ្រងនៅផ្ទះសំណាក់បារាំង មិនថាអ្នកយាមកាម ជាអ្នករៀបចំថែសម្អាត និងជាអ្នកទទួលភ្ញៀវផងដែរ។

គាត់ធ្វើការនេះតែពីរនាក់ប៉ុននោះជាមួយភរិយាគាត់ឈ្មោះលៀង។

ប្ដីប្រពន្ធនេះមិនមានកូនទេ។ បើតាមដែលគេបានជួបកាលពីព្រឹកម្ដងហើយបានជជែកគ្នាលេងបន្តិចបន្តួចមុនពេលចូលសម្រាក ឃើញថាពួកគាត់ស្លូតបូតរាក់ទាក់។

ឥឡូវនេះត្រូវសំឡេងចម្រៀងអាថ៌កំបាំង ដាស់ឱ្យក្រោយចេញមករំខានថ្មើរណោះម៉ោង១អធ្រាត្រឱ្យគត់......

«សុំទោសដែលរំខានបងសម្រាន្ត!»

«អត់មានរំខានអីទេ! ទម្លាប់ខ្ញុំទៅហើយគេងមិនដែលលក់ងាយសោះ!»

«ប៉ុន្តែខ្ញុំ...គេងលក់ទេតើបង! គ្រាន់តែ...ដូចឮអ្នកណាច្រៀងល្វើយៗ...ប្រពន្ធបងហ្មែន?»

ឆោមផ្លាស់ទឹកមុខមួយរំពេច។ សភាពអ្នកនិពន្ធក្មេងកំពុងនិយាយមិនដូចជាកំពុងលេងសើចទេ ហេតុនេះហើយបានជាម្ចាស់ទឹកដី កើតមានចំងល់ពិភាល់លើផ្ទៃមុខ។

ឈ្មោះឆោមនេះគាត់មានវ័យជាងសែសិបឆ្នាំប៉ុននោះ ប៉ុន្តែភិនភាគហាក់ចាស់ជាងអាយុ ដោយសារទំនងជាមនុស្សមានជីវិតហត់នឿយនិងស្គមស្គាំងធ្វើការទ្រុឌទ្រោមប្រើកម្លាំងកាយខ្លាំង។

«អ្នកណាគេបង ច្រៀងឡើងគ្រលួចកណ្តាលអធ្រាត្រ! សំងំយូរទៅ ប៉ះត្រចៀកឡើងៗ»

«ម៉េចក៏ខ្ញុំមិនឮ?!»

«ខ្ញុំឮច្បាស់ណាស់បង! ច្រៀងរហូតទាល់តែខ្ញុំភ្ញាក់ពីគេងឡើងបានណ៎!»

គាត់ឮត្រង់ណោះ ចាប់សើចក្អាកក្អាយបន្លប់សភាពឆ្ងើងឆ្ងល់និងពិភាល់នៅលើផ្ទៃមុខអម្បាញ់មិញ។

«លោកគ្រូយល់សប្តិហើយថាមិនយល់សប្តិ! តោះបងទៅរក ទឹកត្រជាក់ៗមកហូបជជែកគ្នាលេង!»

«បាទបង!»

បុរសវ័យកណ្តាលក្រោកពីអង្រឹងចូលទៅផ្ទះបាយដែលនៅក្បែរៗនេះ។ ក្រោមពន្លឺភ្លើងសូឡាតិចតួច ទីតាំងនេះហាក់គួរសមហើយបើធៀបនឹងកន្លែងដទៃក្នុងភូមិនេះ។

ស្រុកនេះមិនមានអ្នកស្នាក់នៅទេ សូម្បីទីនេះក៏មានតែបីនាក់នេះដែរ។

ម៉្យាងនេះមិនមែនជាថ្ងៃសម្រាកឬក៏ថ្ងៃបុណ្យ ប៉ុន្តែប្រាថ្នាចូលចិត្តស្នាក់នៅក្នុងសភាពស្ងប់ស្ងាត់បែបនេះនឹងអាចបានជជែកលេងសួរនាំច្រើនជាមួយអ្នកមូលដ្ឋានដូចជាបងឆោមនេះឯង។

ប្រសិនបើមានភ្ញៀវច្រើនគាត់ទំនងជាមិនមានពេលក្នុងការនិយាយប្រាប់គេអំពីរឿងផ្សេងៗក្នុងគម្រោងចង់ដឹងរបស់គេទេ។

អាកាសធាតុត្រជាក់ឡើងៗជាលំដាប់ក្រោមស្រទាប់សន្សើម។ គេដាក់អង្គុយលើកៅអីឈើក្បែរអង្រឹង។ ប្រហែលមុននេះ បងឆោមបានអង្គុយជជែកជាមួយភរិយាគាត់។

បុរសនោះវិលត្រលប់មកវិញនិងមានទឹកពីរដបផង។ គាត់ដាក់ខ្លួនអង្គុយមកលើអង្រឹងវិញ ដោយហុចទឹកសុទ្ធមួយដបឲ្យទៅតួប្រុសយើងនឹង។

«អរគុណបងឆោម! បងស្រីសម្រាន្តបាត់ហើយ?!»

«ប្រហែលជាលក់បាត់ហើយមើលទៅ! ខ្យល់ត្រជាក់ត្រជាក់អ៊ីចឹងៗ បានអីនៅ!»

«បង! អាកាសធាតុនៅកន្លែងនេះល្អណាស់ខ្ញុំពិតជាមិនខកបំណងទេ!»

«ប៉ុន្តែហេតុអីលោកគ្រូមកតែម្នាក់ឯង?»

«ជីវិតអ្នកនិពន្ធតែប៉ុណ្ណឹងឯងបង!»

«លោកគ្រូមកនិពន្ធរឿងអីដែរ?!» បុរសសួរបន្តទាំងមួលគ្របបើកដបទឹកបម្រុងផឹកផ្សើម ក។

«បាទ គឺសរសេររឿងនាងកេសនា!»

គម្របទឹកសុទ្ធទម្លាក់ធ្លាក់ចេញពីម្រាមដៃបុរសនោះរមៀល តុក តុក តុក ហួសឆ្ងាយពីរបៀងផ្ទះនេះធ្លាក់ទៅក្នុងជម្រាលដីសួនផ្កា ធ្វើឱ្យបុរសនេះលែងគិតចង់ប្រដេញទៅរើស។

ប៉ុន្តែអាការៈរបស់គាត់ទេ....ដូចជាស្រទន់ឡាំងកាំង....

ទោះសភាពបុរសនេះចម្លែកៗបណ្ដាលឱ្យអ្នកនិពន្ធកម្លោះចាប់ថ្នាក់បាន ប៉ុន្តែគេធ្វើជាមិនដឹងខ្លួនបន្តសួរនាំគាត់ទៀត៖

«បងឆោមនៅណេះយូរ ប្រហែលដឹងច្រើនពីរឿងព្រេងស្ដីពីមនុស្សស្រីឈ្មោះកេសនា....គឺខ្ញុំចង់សរសេរ....»

មិនរង់ចាំឲ្យប្រាថ្នានិយាយចប់នោះទេ ឆោមចាប់ផ្ដើមឃាត់៖

«ឈប់ៗៗៗ! ឈ្មោះនេះ អឺ....មិនត្រូវហៅទេ! មិនត្រូវហៅទេ! »

ធ្វើមិនដឹងដដែល អ្នកនិពន្ធនិយាយទៀតហាក់វាហី៖

«ឮសូរមកថា មានរឿងព្រេងចាស់ដ៏ល្បីមួយនៅភូមិនេះរាប់រយឆ្នាំមកហើយមែនទេបង?!»

«ប៉ុន្តែ...បងសុំណា៎! កណ្ដាលអធ្រាត្រអ៊ីចឹងកុំនិយាយ! កុំនិយាយអីលោកគ្រូ!»

«ខ្ញុំជាអ្នកនិពន្ធណា៎បង! និយាយមែនទែនទៅ វាជាបំណងពិតដែលនាំខ្ញុំមកដល់កន្លែងនេះ! គឺ...ខ្ញុំចង់សរសេររឿងប្រលោមលោកមួយ!»

«ប្រលោមលោក? អឺ...គឺ...ប៉ុន្តែសរសេរ...សរសេរពីរឿងអីទៅ?!»

«គឺ....ជម្រាបមិញម្ដងហើយ! ខ្ញុំចង់សរសេរអំពីមនុស្សស្រីម្នាក់នៅក្នុងរឿងព្រេងនិទានភូមិបងនេះ! ឈ្មោះដែលខ្ញុំនិយាយអម្បាញ់មិញហ្នឹងណាបង....កេសនា!»

គាត់ដាក់ដបចុះ ទាំងដែលក្រេបមិនទាន់ដល់ក្អឹកទីពីរផង។

បុរសនេះអស់ទ្រាំហើយ គឺធ្វើមុខដូចជាភ័យភិត។ លុះក្រឡេកមកឃើញទឹកមុខអ្នកនិពន្ធហាក់កំពុងច្បាស់លាស់ពេកក្នុងការរង់ចាំចម្លើយ អាចថាមានសញ្ញាចំអកឲ្យគាត់ផង បានជាឆោមខំលេបទឹកមាត់ ពង្រឹងស្មារតីឡើងវិញកុំឲ្យចាញ់ប្រាបអ្នកភ្នំពេញដែលកំពុងតែសង្កេតទឹកមុខ។

បានឱកាសប្រាថ្នានិយាយបន្ថែម៖

«ឮសួរថាដោយសាររឿងមួយនោះ ភូមិនេះត្រូវបានគេបោះបង់ចោលច្រើនជំនាន់ រហូតដល់សម័យនេះមែនដែរឬទេ? បងឆោមជាមនុស្សដំបូងគេដែលវិលមករស់នៅកន្លែងនេះវិញ ទាំងខ្លួនឯងមិនមែនជាអ្នកស្រុកដើម?!»

«អ្នកណាជម្រាបលោកគ្រូ!»

«គឺ....បាទ ខ្ញុំស៊ើបរឿងនេះតាមអ៊ីនធឺណេត ចំណែករឿងបងខ្ញុំសួរថៅកែបារាំងរបស់បងតាមឈែត!»

គាត់ដកដង្ហើមវែង៖

«ឪពុកខ្ញុំជាអ្នកស្រុកនេះ! សំខាន់គឺមកពីខ្ញុំទ័លទេ បានជាខ្ញុំសុខចិត្តនាំប្រពន្ធត្រលប់មកវិញ! គ្រពេកមិនមានរបរអីច្បាស់ ហើយក៏បានជួបបារាំងពីរនាក់ប្ដីប្រពន្ធនេះ គាត់មកទិញដីបាន ហើយគ្រោងកសាងផ្ទះសំណាក់មួយនេះឡើង! ទុករួចជាមកដេកចាំដីចម្ការឲ្យគាត់ ខ្ញុំក៏មកនៅប្រាំខែហ្នឹងទេ! ឃើញថា សុខសប្បាយ!»

«អូ៎ និយាយពីរឿងក្មេងស្រីដែលត្រូវគេរំលោភហើយសម្លាប់ខ្លួនកាលពីសម័យបុរាណហ្នឹងណ៎ា បងដឹងដែរតាស៎ហ្អី?!»

គាត់បើកភ្នែកធំៗហើយទ្រេតខ្លួនទៅលើអង្រឹងវិញធ្វើដូចចង់គេង ចង់គេច។

អ្នកនិពន្ធដែលតាមសម្គាល់ទឹកមុខ ប្រាកដជាយល់ច្បាស់ណាស់ថា បុរសនេះប្រាកដជាបានដឹងឮអំពីតំណាលតៗគ្នារយឆ្នាំមកហើយនោះ។ មានឯកសារបុរាណមកថា ទាសករមិនទាន់គ្រប់អាយុពេញដោយសម្រស់ឆោមលោមពណ៌ម្នាក់ឈ្មោះនាងកេសនា ជាកូនស្រីរបស់ខ្ញុំបម្រើដែលគ្មានសិទ្ធិហាស្ដី ប្រកែកប្រណាំងអ្វីជាមួយនឹងក្រុមម្ចាស់ផ្ទះឡើយ ។

បុរសអភិជនអាយុជាងហុកសិបឆ្នាំម្នាក់ដែលស្មើនឹងជីតារបស់នាង បានកេសនារំលោភសេពសន្ធវៈនៅរាត្រីកាលមួយ។ បន្ទាប់មកអ្នកស្រុកបានដឹងថា នាងបានសម្លាប់ជីវិតខ្លួនឯងចោល។

ក្រោយមកស្រុកភូមិនេះ ក៏ចាប់ផ្ដើមជួបប្រទះរឿងហេតុចម្លែកៗជាច្រើន។ អ្នកស្រុកដើមហៅថាជាវិញ្ញាណសងសឹករបស់ក្មេងស្រីនេះរហូតចំណេរក្រោយៗមនុស្សប្រុសទាំងអស់នៅក្នុងត្រកូលក្ដីនោះ ឬសូម្បីតែអ្នកបម្រើប្រុសដូចគ្នាក៏ត្រូវបានវិញ្ញាណតាមសម្លាប់ដោយប្រការផ្សេងៗ។

គេបានធ្វើការស្រាវជ្រាវចំពោះពាក្យចចាមអារ៉ាមនិងរឿងនិទាននេះយូរណាស់មកហើយទម្រាំដាច់ចិត្តថាមកដល់ភូមិនេះ។

«ជាងពីរឆ្នាំមុន ខ្ញុំធ្លាប់ចង់មកភូមិនេះម្តងដែរបង ប៉ុន្តែមិនទាន់មានអ្នកណានៅ ហើយគ្មានកន្លែងស្នាក់ផង! បានបបួលមិត្តភក្តិឲ្យមកចងតង់គេង ក៏គ្មានអ្នកណាព្រមមកតាម! គេថាមិនមានទឹកស្អាត មិនមានបន្ទប់ទឹក! មិនមានអាហារ...!»

បងឆោមនៅតែមិនមាត់ មិនក គាត់ហាក់សំងំគេងគងថ្វាសស្ងៀមស្ងាត់។

«ប៉ុន្តែឥឡូវនេះគ្រប់យ៉ាងមានហើយ! ខ្ញុំនឹងគេងនៅណេះ សរសេរសៀវភៅនេះឲ្យចប់!»

«សៀវភៅអីទៅ?! សុំម្តងទៀត! បងជាមនុស្សបញ្ញាខ្សោយណាស់ ស្តាប់មិនបានទេ!»

«ខ្ញុំដាក់ចំណងជើងថា តួស្រីក្នុងរឿងព្រេង! គឺព្រេងកថាដែលគេបានតំណាលតគ្នានៅណេះណ៎ាបងឆោម!»

«រឿង...រឿង...»

គាត់ប្រុងប្រាប់អ្វីម៉្យាង ឬប្រុងសួរ ប្រុងប្រកែក តែនិយាយមិនរួច បានត្រឹមពីរមាត់ហើយរលត់វិញ។

អ្នកនិពន្ធយើងបានឱកាសក៏បន្តភ្លាមពីលើគំនិតគាត់៖

«ខ្ញុំចង់ប្រាប់អ្នកអានខ្ញុំថា គ្រប់យ៉ាងនៅណេះ គ្រាន់តែជារឿងព្រេង! មិនមែនជាការពិតនោះទេ! លោកនេះគ្មានវិញ្ញាណគ្មានខ្មោចព្រាយបិសាចឡើយ!»

«បើសិនជាលោកប្អូនគ្រូ នៅតែនិយាយអំពីរឿងហ្នឹងទៀតបងសុំសម្រាកហើយ! យប់ជ្រៅហើយណ៎ា យប់ជ្រៅហើយ! ស្អែកបងត្រូវតែកាប់ចម្ការផង!»

ចេតនារបស់គាត់ គឺបង្ហាញច្បាស់នៅនឹងមុខរបស់ប្រាថ្នាថា គាត់នឹងមិននិយាយរឿងទាំងអស់នោះ មួយម៉ាត់ណាឡើយទោះបីជាគេមានព័ត៌មានជាច្រើន គេគ្រាន់តែចង់បានសាក្សីម្នាក់ ដើម្បីកំណត់ធ្វើជាប្រភពច្បាស់លាស់នៅក្នុងសៀវភៅរបស់គេ។

បុរសអ្នកភូមិបិទភ្នែកគេច។

អ្នកនិពន្ធច្រត់ដៃក្រោកទាំងបង្ខំចិត្តដែរ។

«រាត្រីសួស្តីបង!»

គេដើរមួយៗតម្រង់មកបន្ទប់វិញដោយគ្មានឮសំនៀងអ្វីក្រៅពីស្នូរទង្គិចស្លឹកឈើឡើយ។

ភូមិនេះពិតជាស្ងាត់ណាស់។ ចូលទៅបន្ទប់វិញយុវបុរសនៅតែឱបក្ដីសង្ឃឹមថា គេនឹងរកឃើញអាថ៌កំបាំងនៃបទចម្រៀងដែលគ្មានប្រភពនេះមិនខាន។

មនុស្សស្រីដែលចេះចម្រៀងបុរាណម្នាក់នោះ អាចថាបានដឹងឮរឿងនិទានអំពីនាងទាសករឈ្មោះកេសនាច្រើនជាងបងឆោមម្នាក់នេះផង?

ប៉ុន្តែអ្នកភូមិនៅក្បែរនេះហោចណាស់ក៏រស់នៅកន្លះគីឡូម៉ែត្រពីផ្ទះសំណាក់បារាំងដែរ គឺនៅផ្លូវបំបែកក្បែរផ្សារឯណោះ ជាផ្លូវចូលមកភូមិ ពួកគេច្រៀងឮមកដល់ទីនេះបាន?

តែបើសិនជាប្រពន្ធបងឆោម ជាអ្នកច្រៀងហេតុអីបានជាខាងប្ដីអះអាងថាមិនបានឮ?

គិតរហូតលង់លក់ក្នុងដំណេក....គ្មានទៀតទេ...ចម្រៀងបុរាណ...

«លោកគ្រូៗ! ពិសាបបរ!»

គេកម្រើកភ្នែកតិចៗ។

នេះគេងដល់ថ្ងៃចាំងគូទហើយ? គេងរហូតម្ចាស់កន្លែងមកដាស់បបរ?

គេស្ទុះបើកទ្វារឃើញបងលៀងញញឹមស្រស់។

«សុំទោសបងដាស់ ព្រោះប្រញាប់ទៅចម្ការ! លោកគ្រូពិសាបបរ ត្រីប្រឡាក់! ហើយណេះកាហ្វេមិនដឹងថាលោកគ្រូចូលចិត្តទេ! កាហ្វេអ្នកស្រុកក្បែរយើងហ្នឹង គេដាំធម្មជាតិ ថៅកែបារាំងគាត់ចូលចិត្តណាស់!»

សុភាពបុរសញីភ្នែក សោមនស្សខ្លាំងនឹងក្លិនកាហ្វេជះមកឈ្ងុយសែនឈ្ងុយ។ ភេសជ្ជៈនេះប្រាកដណាស់ជាថាមពលពេញថ្ងៃសម្រាប់នាយយើងហើយ។ គេវាចាតបស្រស់បស់៖

«ប្អូនចង់សុំទៅលេងចម្ការដែរ! ហើយណេះធីបរបស់បងស្រី!»

ធម្មតាអាហារនិងជម្រកគេបានបង់តាមអ៊ីនធឺណេតដល់បារាំងជាម្ចាស់គេហដ្ឋានទៅហើយ ចំណែកឯការបម្រើរបស់ស្ត្រីនេះទៀតសោត លើអាហារបី ពេលពិតជាឆ្ងាញ់និងផ្ចិតផ្ចង់ណាស់ គេសម្គាល់និងកោតសរសើរតាំងពីថ្ងៃម្សិលមិញ។

«ច្រើនណាស់លោកគ្រូ!» លៀងលាន់មាត់ពេលសម្លឹងលុយ២០០០០រៀលលើថាស។

«មិនច្រើនទេបង! បងស្រីធ្វើការបានល្អណាស់! អរគុណបង!»

«អ៊ីចឹងបងរង់ចាំលោកគ្រូ កន្លះម៉ោងទៀតទៅចម្ការទាំងអស់គ្នា!»

«បាទ អរគុណបង!»

ស្រីនេះមានម៉ូតូចាស់មួយ បានដឹកគេកាត់តាមភូមិតូចៗក្បែរខាង ជាការទស្សនាសិនមុនពេលបកទៅចម្ការប្រមាណជា៣០០ម៉ែត្រពីក្រោយទីសំណាក់។

នៅជុំវិញមិនឃើញវាលស្រែចម្ការ មិនឃើញមានផ្ទះអ្នកភូមិច្រើនដូចនៅឯផ្សារ ប៉ុន្តែនៅជាយច្រកចូលភូមិនេះ មានផ្ទះលក់គ្រឿងភេសជ្ជៈនិងសាំងបារីពីរបីកូនស្តង់រស់នៅផ្តុំជាប់គ្នា ឆ្ងាយប្រមាណជា៥០០រយម៉ែត្រពីផ្ទះសំណាក់និងចម្ការមួយនេះ។

និយាយពីចម្ការរបស់ប្តីប្រពន្ធបារាំងមួយគូនេះ ចោមព័ទ្ធទៅដោយវាលរាប់សិបហិកតាសឹងជាដីមានជីវជាតិស្តាយត្រង់ទឹបនឹងត្រូវបានទិញយកហើយ គ្រួសារបារាំងចាប់ផ្តើមកាប់គាស់ពង្រោះដើមនៃរុក្ខជាតិតូចធំ ពុំនោះដីដ៏មានគុណភាពសក្តិសមនឹងដំណាំគ្រប់យ៉ាងនេះ មិនដឹងថាត្រូវនៅសោះកក្រោះរហោឋានដល់ពេលណាទេ។

ពួកគេបានចាប់ផ្តើមដំណាំជាច្រើនប្រភេទដូចជាផ្លែល្មើ និងស្វាយ ម្នាស់ដូង ប៉ុន្តែមិនទាន់រកបានកម្មករច្រើនគ្រប់នៅឡើយសម្រាប់ជួយគ្នា។

ប្តីប្រពន្ធនេះប្រាប់មកប្រាថ្នាថា កម្មករភាគច្រើនស្នាក់នៅនៅស្រុកជាប់ខាង។ ពួកគេមកតែពេលថ្ងៃដើម្បីជួយបាញ់ទឹកនិងសម្អាតដីខ្លះប៉ុន្តែមិនទាន់បានអ្នកជំនាញមកទេ។ អ្នកជំនាញត្រូវរកមកពីទីឆ្ងាយៗ ហើយត្រូវស្នាក់នៅ គឺរកមិនទាន់បាន។

និយាយរួម ប្រាថ្នាដឹងថាមិនមានអ្នកណាហ៊ានសម្រេចចិត្តប្រថុយមកស្នាក់នៅទីនេះប្រសិនគេជាអ្នកមានជំនឿលើរឿងខ្មោចព្រាយ ក៏ដោយសារតែឥទ្ធិពលនៃបណ្តាពាក្យចចាមអារាមពីអតីតកាលគួរឱ្យពួកគេភ័យខ្លាចនិងសង្ស័យ។

«អាវរបស់លោកគ្រូស្អាតខ្លាំងណាស់!»

ពាក្យបងឆោមសរសើរ ធ្វើឱ្យអ្នកនិពន្ធឱនសម្លឹងអាវថ្មីមួយដែលខ្លួនពាក់នៅថ្ងៃនេះ អាវមួយធ្វើអំពីហូលសូត្រសុទ្ធ។ ប្រាថ្នាតាមពិតមានបំណងចង់ពាក់អាវនេះ មកថតរូបផ្តិតដាក់នៅក្នុងសៀវភៅបន្ទាប់ពីគេសរសេររឿងនេះចប់។

«បាទ! ខ្ញុំពាក់មកថតរូប ផ្តិតលើសៀវភៅថ្មីណា៎បង! បងឆោមចាំជួយថតឲ្យផងបង!»

«បងថតឲ្យបាន! បងចេះថតបង្ហោះស្អាតណាស់! ដែលរូប Resort យើងបង្ហោះលើ internet ទាំងអស់ហ្នឹង បងអ្នកថតផ្ញើទៅថៅកែទាំងអស់!»

«តែបងអ្ហា! អត់ទេបង! មានវាលភក់មួយ ដែលគេល្បីថា...មានដើមឈើទាលរយឆ្នាំនោះ...»

គេនិយាយដល់ណោះក៏បង្អង់បន្តិច ខណៈប្តីប្រពន្ធពិតជាថ្លោះទឹកមុខ។ ដូចការស្មានប្រាថ្នា និយាយបន្ថែមភ្លែតៈ

«ខ្ញុំចង់ទៅថតនៅក្បែរដើមឈើទាលនោះវិញបង!»

មិនឲ្យទាំងពីរនាក់ប្តីប្រពន្ធបិទមាត់ដូចគេចុកយ៉ាងម៉េចកើត បើអ្នកនិពន្ធកម្លោះនេះដឹងមកស្រេចហើយថា ដើមឈើទាលនិងវាលភក់ គឺជាកន្លែងដែលមានតំណាលតៗមកថា ក្មេងស្រីបានចងកសម្លាប់ខ្លួនឯងនៅក្រោមគល់នោះ។ ក្រោយមកសាកសពទាំងអស់នៅក្នុងគ្រួសារក្តុម្ពីរ ដែលត្រូវបានស្លាប់បន្តបន្ទាប់ ក៏រកឃើញនៅតំបន់នោះដែរ។ ដោយសារបែបនេះ អ្នកភូមិក៏រើចេញពីទីនោះឆ្ងាយៗរាប់គីឡូដី ទុកវាថាជាទីរហោឋាន។

ទោះយ៉ាងណា ដើមឈើទាលនៅតែបន្តរស់រានមានជីវិតនៅរាប់រយឆ្នាំ។

ក៏មានឯកសារលើអ៊ីនធឺណេតអះអាងថាកាលពីជំនាន់បារាំង ក៏ធ្លាប់មានគេចង់កាប់វាចោលដែរ ប៉ុន្តែវានៅតែជាប់មឹងនៅទីនោះបានដដែលហើយគ្រួសាររាជការដែល ដឹកនាំបញ្ជាបារាំងមកកាប់បំផ្លាញក៏សឹងត្រូវស្លាប់ផុតពូជដោយមិនដឹងហេតុ។ អំណើះតមក ក៏លែងមានអ្នកណាហ៊ានពើងទ្រូងមកប៉ះពាល់តំបន់នោះទៀត។ វាក្លាយជាកន្លែងគ្មានម្ចាស់មកទល់សព្វថ្ងៃ.....

«កុំ កុំ កុំ! កុំទៅថតនៅកន្លែងនោះ! គ្មានស្អីស្អាតនោះទេប្អូនគ្រូ!»

បងលៀងខំឃាត់ខ្សឹបៗទាំងមុខស្លាំងស្លេក។